# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១៣

## ជប៉ុនផ្តល់១២០,៧៨០ដុល្លារអាមេរិក សម្រាប់គម្រោងសាងសង់ ក្លឹបហ្វឹកហាត់ក្បាច់គុនយុទ្ធសិល្បជប៉ុន



លោក ហ៊ីហ្គូជិ យ៉ូស៊ីហ៊ីរ៉ូ និងលោក ឡាច ច័ន្ទសុវណ្ណ

ក្រោមគ្រោងការណ៍នៃជំនួយឥតសំណង សម្រាប់គម្រោងទ្រង់ទ្រាយតូចផ្នែកវប្បធម៌ រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន ១២០,៧៨០ ដុល្លារអាមេរិកដល់ខេមរៈសហព័ន្ធការ៉ាតេ-ដូ។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាថ្ងៃនេះដោយលោក ហ៊ីហ្គូជិ យ៉ូស៊ីហ៊ីរ៉ូ ភារៈធារីស្តីទីស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង លោក ឡាចច័ន្ទសុវណ្ណ ប្រធានខេមរៈសហព័ន្ធ ការ៉ាតេ-ដូ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC)។

ដើម្បីលើកស្ទួយវិស័យក្បាច់គុនយុទ្ធសិល្បជប៉ុនក្នុងប្រទេសកម្ពុជា ខេមរៈសហព័ន្ធការ៉ាតេ-ដូ នឹងអនុវត្តគម្រោងសាងសង់ក្លឹបហ្វឹកហាត់មួយ ដែលមានកម្ពស់ពីរជាន់ក្នុងរាជធានីភ្នំពេញ។ ជាផ្នែកមួយក្នុងគម្រោងនេះដែរ សម្ភារៈនិងឧបករណ៍ចាំបាច់សម្រាប់រៀបចំការប្រកួតក៏នឹងត្រូវបានបំពាក់ផងដែរ។ យើងរំពឹងថា អ្នកហ្វឹកហាត់ការ៉ាតេជាង៤០០នាក់នឹងអាចហ្វឹកហាត់ ក៏ដូចជាធ្វើការប្រកួតនៅក្នុងសាលហ្វឹកហាត់ថ្មីនេះ។ ជាងនេះទៅទៀត គម្រោងនេះនឹងរួមចំណែកដល់ការបង្កើនចំនួនអ្នកហ្វឹកហាត់ក្បាច់គុនយុទ្ធសិល្បជប៉ុនក្នុងប្រទេសកម្ពុជា ហើយជាមួយគ្នានេះ នឹងបង្កើនការយល់ដឹងរបស់ប្រជាជនកម្ពុជាអំពីវប្បធម៌ជប៉ុន។





សុន្ទរកថាថ្លែងដោយលោក ហ៊ីហ្គូជិ យ៉ូស៊ីហ៊ីរ៉ូ

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចផ្នែកវប្បធម៌របស់ប្រទេសជប៉ុនមានគោលបំណងគាំទ្រដោយផ្ទាល់ចំពោះការអនុវត្តគម្រោងវប្បធម៌ កីឡា និងការអប់រំកម្រិតឧត្តម ព្រមទាំងគម្រោងថែរក្សាវប្បធម៌កេរតំណែលដែលអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាលដែលកំពុងធ្វើសកម្មភាពនៅកម្រិតមូលដ្ឋានក្នុងប្រទេសកំពុងអភិវឌ្ឍន៍។



រូបថតអនុស្សាវរីយ៍




ការបង្ហាញក្បាច់គុនការ៉ាតេក្រោយពិធីចុះហត្ថលេខា

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៩-៣៣០*

*អ៊ីមែល: eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*